គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia
និយ័តករបរធនបាលកិច្ច
Trust Regulator
លេខ ៥១ ចេញផ្សាយថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២
No.51 Released on 8 August, 2022
អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# អត្ថប្រយោជន៍នៃការចុះបញ្ជីបរធនបាលកិច្ចបុគ្គល

## Benefit of Personal Trust




រូបភាព | Picture: https://www.empruntis.com/assurance-pret-immobilier/actualites/assurance-emprunteur-stop-aux-idees-recues-sur-lassurance-de-pret-immobilier,8360

យោងតាមមាត្រា១៣ នៃច្បាប់ស្តីពីបរធនបាលកិច្ច÷ “បរធនបាលកិច្ចបុគ្គលត្រូវបានបង្កើតឡើងសម្រាប់ជាប្រយោជន៍របស់បរធនបាលទាយកឬបុគ្គលដែលកំណត់ជាក់លាក់ដោយបរធនបាលទាយក[...]”។ តាមស្មារតីនៃមាត្រា១៣ នៃច្បាប់ស្តីពីបរធនបាលកិច្ចនេះ សាធារណជនតែងតែមានចម្ងល់ថាតើបរធន-បាលកិច្ចបុគ្គលបានផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់អ្នកបង្កើត (បរធនបាលទាយក)។

ដូច្នេះការចុះបញ្ជីបរធនបាលកិច្ចបុគ្គលផ្តល់អត្ថប្រយោជន៍ដល់បរធនបាលទាយកដូចខាងក្រោម÷ (១)មានពេលវេលាផ្ទាល់ខ្លួនមានទំនុកចិត្ត ដោយមិនបាច់ព្រួយបារម្ភអំពីទ្រព្យសម្បត្តិគ្មានអ្នកគ្រប់គ្រង ចាត់ចែង និងថែរក្សាជំនួសបរធនបាលទាយក(២)ពុំមានការភ័យខ្លាច អំពីការបាត់បង់ទ្រព្យសម្បត្តិដែលបានផ្ទេរឱ្យអ្នកដទៃ (បរធនបាល)ជាអ្នកគ្រប់គ្រង ចាត់ចែង និងថែរក្សា ជំនួសពីព្រោះដោយសារការចុះបញ្ជីបរធនបាលកិច្ចបុគ្គល នៅនិយ័តករបរធន-បាលកិច្ច គឺជាយន្តការស្របច្បាប់ច្បាស់លាស់ដែលធានា អំពីកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតរបស់បរធនបាលទាយក និងធានាថាបរធនបាល-កិច្ចបុគ្គល នេះពិតជាបានអនុវត្តស្របតាមគោលបំណង ដើមរបស់បរធនបាលទាយក, (៣)អាចទទួលបានអត្ថប្រយោជន៍ចេញពីការគ្រប់គ្រង ចាត់ចែង ថែរក្សារ សុវត្ថិភាពជំនួសបរធនបាល (៤)នៅពេលមិនទាន់ទទួលបានអត្ថប្រយោជន៍ ទោះបីជាបរធនបាលទាយកមានការប្រែប្រួល ខាងសម្ថភាពផ្នែករាងកាយ ផ្នែកស្មារតី ឬមានការប្រែប្រួលផ្នែកណាមួយផ្សេងទៀត ក៏អាចបន្តទទួលបានផលប្រយោជន៍ ហើយអាចបែងចែកផលប្រយោជន៍ទៅ សាច់ញាតិ ឬក្រុមគ្រួសារ ទោះបីជាបរធនបាលទាយក មានការប្រែប្រួល ខាងសម្ថភាពផ្នែករាងកាយ ផ្នែកស្មារតី ឬផ្នែកណាមួយផ្សេងទៀតក៏ដោយ (៥)ករណីដែលបរធនបាលទាយក ទទួលមរណៈភាព បរធនបាល និងគ្រប់គ្រង ចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិជាបរធនជំនួស បរធនបាលទាយក ស្របតាមគោលបំណងដើមរបស់បរធនបាលទាយក ដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច ជៀងវាងការអនុវត្តស្នុកស្មាញ នឹងចំណាយពេលវេលាយូរ (Aviod Probate) តាមមធ្យោបាយផ្សេងទៀត។




ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

According to Article 13 of the Law on Trust: "Individual trust is established for the benefit of the Trustor or the person specified by the Trustor [...]". In the spirit of Article 13 of the Law on Trust the public often wonders that what benefits the personal trust provides to the creators (trustor).

Therefore, the registration of personal trust will provide benefits for the trustor/settlor such as: (1) Having personal time without concerning about to having no one to control manage and guard the asset, (2) Don't have to worry about losing property transferred to another person (Trustees) to be managed and guard, because through personal trust Registration, Trust Regulator is the legal mechanism that guarantees the ownership and other rights of the trustor on the asset and ensures trustee will obey with the original purpose of the trustor, (3) Can get benefit from management and guarding instead of the trustees.
(4) When the beneficiary has not yet received benefits, even if there is a change in the physical, mental or other physical changes, the benefits can continue to be shared and the benefits can be distributed to relatives or family, even if the caregiver changes in physical, mental, or other abilities (5) In case trustor pass away, trustees will manage, transfer and safekeep the trust assets as properly for trustor in accordance with the original purpose of trust creator defined in trust instrument to avoid complicated practices and to avoid probate by other means.

អត្ថបទ÷ ឆែម គឹមហ៊ង | Article: Chhem KimHourng

ឯកសារយោង | References:

- ច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩)
- អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ (២០១៣)
- ប្រកាសស្តីពីវិធានគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច (២០២២)

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.